Retreat BEHAVIORAL HEALTH

# ការការពារនិងសិទ្ធិរបស់អ្នកប្រឆាំងនឹងវិក្កយបត្រវេជ្ជសាស្ត្រដោយមិនដឹងខ្លួន

នៅពេលដែល អ្នក ទទួលបាន ការថែទាំ សង្គ្រោះបន្ទាន់ ឬ ត្រូវ បានព្យាបាល ពី អ្នក ផ្តល់សេវា ក្រៅបណ្តាញ នៅ មន្ទីរពេទ្យ ក្នុងបណ្តាញ ឬ មណ្ឌលវះកាត់អ្នកជំងឺក្រៅ អ្នកត្រូវបានការពារ ពី ការចេញវិក្កយបត្រចំនួនប្រាក់នៅសល់។ នៅក្នុងករណីទាំងនេះ អ្នក មិនគួរ ត្រូវគេគិតប្រាក់ លើសពីប្រាក់ទូទាត់រួម សហធានារ៉ាប់រង និង/ឬ ប្រាក់កាត់កងនៃគម្រោងរបស់អ្នកទេ។

**តើ “ការចេញវិក្កយបត្រចំនួនប្រាក់នៅសល់” (ពេលខ្លះគេហៅថា “ការចេញវិក្កយបត្រដោយមិនដឹងខ្លួន”) ជាអ្វី?**

នៅពេលដែលអ្នកទៅជួបពេទ្យ ឬអ្នកផ្តល់សេវាថែទាំសុខភាពផ្សេងទៀត អ្នកអាចជំពាក់ ថ្លៃចំណាយប្រាក់ហោប៉ៅក្នុងចំនួនណាមួយ ដូចជា ប្រាក់ទូទាត់រួម, សហធានារ៉ាប់រង ឬ ប្រាក់កាត់កង។ អ្នកអាចត្រូវចំណាយបន្ថែម ឬត្រូវបង់វិក្កយបត្រទាំងមូលបើសិនជាអ្នកទៅជួបអ្នកផ្តល់សេវា ឬទៅមណ្ឌលថែទាំសុខភាពដែលមិនមែននៅក្នុងបណ្តាញគម្រោងសុខភាពរបស់អ្នក។

“ក្រៅបណ្តាញ” មានន័យថាអ្នកផ្តល់សេវា ឬមណ្ឌលដែលមិនបានចុះកិច្ចសន្យាជាមួយគម្រោងសុខភាពរបស់អ្នកដើម្បីផ្តល់សេវា។ អ្នកផ្តល់សេវាក្រៅបណ្តាញអាចទទួលការអនុញ្ញាតឱ្យចេញវិក្កយបត្រឱ្យអ្នកនូវផលសងរវាងប្រាក់ដែលគម្រោងរបស់អ្នកបង់ និងចំនួនប្រាក់ពេញដែលគេគិតសម្រាប់ថ្លៃសេវា។ នេះគេហៅថា “**ការចេញវិក្កយបត្រចំនួនប្រាក់នៅសល់**។” ចំនួននេះទំនងជាច្រើនជាងថ្លៃក្នុងបណ្តាញសម្រាប់សេវាកម្មដូចគ្នា ហើយអាចនឹងមិនគិតចូលប្រាក់កាត់កងនៃគម្រោងរបស់អ្នក ឬដែនកំណត់ប្រាក់ចំណាយពីហោប៉ៅប្រចាំឆ្នាំទេ។

“ការចេញវិក្កយបត្រដោយមិនដឹងខ្លួន” គឺជាវិក្កយបត្រចំនួនប្រាក់នៅសល់ដែលមិនបានគិតទុកជាមុន។ រឿងនេះអាចកើតឡើងនៅពេលដែលអ្នកមិនអាចគ្រប់គ្រងថាអ្នកណាដែលពាក់ព័ន្ធនឹងការថែទាំរបស់អ្នក ដូចជាពេលដែលអ្នកត្រូវសង្គ្រោះបន្ទាន់ ឬនៅពេលដែលអ្នកគ្រោងទៅជួបមណ្ឌលក្នុងបណ្តាញ ប៉ុន្តែទទួលការព្យាបាលដោយមិនបានគិតទុកជាមុនពីអ្នកផ្តល់សេវាក្រៅបណ្តាញ។ វិក្កយបត្រវេជ្ជសាស្ត្រដោយមិនដឹងខ្លួនអាចថ្លៃរាប់ពាន់ដុល្លារ អាស្រ័យតាមនីតិវិធី ឬសេវាកម្ម។

**អ្នកត្រូវបានការពារពីការចេញវិក្កយបត្រចំនួនប្រាក់នៅសល់សម្រាប់៖**

**សេវាកម្មសង្គ្រោះបន្ទាន់**

បើសិនជាអ្នកមានស្ថានភាពវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ ហើយទទួលសេវាកម្មសង្គ្រោះបន្ទាន់ពីមណ្ឌល ឬអ្នកផ្តល់សេវាក្រៅបណ្តាញ ចំនួនប្រាក់ច្រើនបំផុតដែលគេអាចចេញវិក្កយបត្រឱ្យអ្នកគឺជាចំនួនប្រាក់បដិភាគក្នុងបណ្តាញនៃគម្រោងរបស់អ្នក

(ដូចជា ប្រាក់ទូទាត់រួម សហធានារ៉ាប់រង និងប្រាក់កាត់កង)។
គេ**មិនអាច**ចេញវិក្កយបត្រចំនួនប្រាក់នៅសល់សម្រាប់សេវាកម្មសង្គ្រោះបន្ទាន់ទាំងនេះឱ្យអ្នកទេ។
នេះរួមទាំងសេវាកម្មដែលអ្នកអាចនឹងទទួលបានបន្ទាប់ពីអ្នកស្ថិតក្នុងស្ថានភាពនឹងនរ
លើកលែងតែអ្នកផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរ
និងបោះបង់ការការពាររបស់អ្នកមិនឱ្យគេចេញវិក្កយបត្រប្រាក់នៅសល់សម្រាប់សេវាកម្មក្រោយពេលស្ថានភាពនឹងនរ

រដ្ឋ Connecticut បានអនុម័តច្បាប់របស់ខ្លួនក្នុងឆ្នាំ 2015 ដើម្បីដោះស្រាយការចេញវិក្កយបត្រចំនួនប្រាក់នៅសល់។ ច្បាប់នេះអនុវត្តចំពោះគម្រោងសុខភាពដែលគ្រប់គ្រងដោយក្រសួងធានារ៉ាប់រងនៃរដ្ឋ Connecticut ហើយមានការការពារស្រដៀងគ្នាទៅនឹងការការពារដែលផ្តល់ឱ្យក្រោមច្បាប់សហព័ន្ធ No Surprises ដែរ។ សម្រាប់ព័ត៌មានបន្ថែម សូមមើល Conn. Gen. Stat. §§ 38a-477aa និង 20-7f ឬវេបសាយក្រសួងធានារ៉ាប់រងរដ្ឋ Connecticut នៅ portal.ct.gov/CID/General-Consumer-Information/No-Surprises-Act។

**សេវាកម្មមួយចំនួននៅមន្ទីរពេទ្យក្នុងបណ្តាញ ឬមណ្ឌលវះកាត់អ្នកជំងឺក្រៅ**
នៅពេលអ្នកទទួលសេវាកម្មពីមន្ទីរពេទ្យក្នុងបណ្តាញ ឬមណ្ឌលវះកាត់អ្នកជំងឺក្រៅ អ្នកផ្តល់សេវាកម្មមួយចំនួននៅទីនោះអាចនៅក្រៅបណ្តាញ។ ក្នុងករណីទាំងនេះ ចំនួនប្រាក់ច្រើនបំផុតដែលអ្នកផ្តល់សេវាកម្មអាចចេញវិក្កយបត្រឱ្យអ្នកគឺចំនួនប្រាក់បដិភាគក្នុងបណ្តាញនៃគម្រោងរបស់អ្នក។ នេះគឺអនុវត្តចំពោះសេវាកម្មថ្នាំសង្គ្រោះបន្ទាន់ ការដាក់ថ្នាំសណ្តំ/ស្ពឹក រោគសាស្ត្រ វិទ្យុសាស្ត្រ មន្ទីរពិសោធន៍ រោគវិទ្យាទារកទើបនឹងកើត ជំនួយការគ្រូពេទ្យវះកាត់ គ្រូពេទ្យប្រចាំនៅមន្ទីរពេទ្យ ឬសេវាកម្មវេជ្ជបណ្ឌិតថែទាំជំងឺធ្ងន់។ អ្នកផ្តល់សេវាទាំងនេះ**មិនអាច**ចេញវិក្កយបត្រចំនួនប្រាក់នៅសល់ឱ្យអ្នក ហើយមិន **អា** សុំឱ្យអ្នកបោះបង់ការការពារមិនឱ្យចេញវិក្កយបត្រចំនួនប្រាក់នៅសល់បានទេ។

បើសិនជាអ្នកទទួលសេវាកម្មប្រភេទផ្សេងទៀតនៅតាមមណ្ឌលក្នុងបណ្តាញទាំងនេះ អ្នកផ្តល់សេវាក្រៅបណ្តាញ**មិនអាច**ចេញវិក្កយបត្រចំនួនប្រាក់នៅសល់ឱ្យអ្នកទេ លើកលែងតែអ្នកផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរនិងបោះបង់ការការពាររបស់អ្នក។

## អ្នក <u>មិន</u> ត្រូវបានទាមទារឲ្យបោះបង់ការការពារពីការចេញវិក្កយបត្រចំនួនប្រាក់នៅសល់នោះទេ។ អ្នកក៏មិនត្រូវបានទាមទារឱ្យទទួលការថែទាំក្រៅបណ្តាញដែរ។ អ្នកអាចជ្រើសរើសអ្នកផ្តល់សេវាកម្ម ឬមណ្ឌលនៅក្នុងបណ្តាញនៃគម្រោងរបស់អ្នក។

រដ្ឋ Connecticut បានអនុម័តច្បាប់របស់ខ្លួនក្នុងឆ្នាំ 2015 ដើម្បីដោះស្រាយការចេញវិក្កយបត្រចំនួនប្រាក់នៅសល់។ ច្បាប់នេះអនុវត្តចំពោះគម្រោងសុខភាពដែលគ្រប់គ្រងដោយក្រសួងធានារ៉ាប់រងនៃរដ្ឋ Connecticut ហើយមានការការពារស្រដៀងគ្នាទៅនឹងការការពារដែលផ្តល់ឱ្យក្រោមច្បាប់សហព័ន្ធ No Surprises ដែរ។ សម្រាប់ព័ត៌មានបន្ថែម សូមមើល Conn. Gen. Stat. §§ 38a-477aa និង 20-7f ឬវេបសាយនៃក្រសួងធានារ៉ាប់រងនៃរដ្ឋ Connecticut គឺ portal.ct.gov/CID/General-Consumer-Information/No-Surprises-Act។

**នៅពេលគេមិនអនុញ្ញាតឱ្យចេញវិក្កយបត្រចំនួនប្រាក់នៅសល់ អ្នកក៏មានការការពារទាំងនេះផងដែរ៖**

- អ្នកទទួលខុសត្រូវតែការបង់ប្រាក់បដិភាគរបស់អ្នកប៉ុណ្ណោះ (ដូចជាប្រាក់ទូទាត់រួម សហធានារ៉ាប់រង និងប្រាក់កាត់កងដែលអ្នកត្រូវបង់ បើសិនជាអ្នកផ្តល់សេវាកម្ម ឬមណ្ឌលស្ថិតនៅក្នុងបណ្តាញ)។ គម្រោងសុខភាពរបស់អ្នកនឹងបង់ថ្លៃបន្ថែមទៅមណ្ឌល និងអ្នកផ្តល់សេវាក្រៅបណ្តាញដោយផ្ទាល់។

- ជាទូទៅ គម្រោងសុខភាពរបស់អ្នកត្រូវតែ៖
  - ធ៉ាប់រងសេវាកម្មសង្គ្រោះបន្ទាន់ដោយមិនទាមទារឱ្យអ្នកទទួលការយល់ព្រមសម្រាប់សេវាកម្មជាមុន (ដែលហៅម្យ៉ាងទៀតថា "ការអនុញ្ញាត ជាមុន" ) ទេ។
  - ធ៉ាប់រងសេវាកម្មសង្គ្រោះបន្ទាន់ ដោយអ្នកផ្តល់សេវាក្រៅបណ្តាញ។
  - ដោយផ្អែកអ្វីដែលអ្នកជំពាក់អ្នកផ្តល់សេវាកម្ម ឬមណ្ឌល (ថ្លៃបដិភាគ) លើអ្វីដែលនឹងបង់ឱ្យមណ្ឌល ឬអ្នកផ្តល់សេវាក្នុងបណ្តាញ និងបង្ហាញចំនួននោះនៅក្នុងការពន្យល់អំពីអត្ថប្រយោជន៍របស់អ្នក។
  - រាប់បញ្ចូលចំនួនប្រាក់ដែលអ្នកបង់សម្រាប់សេវាកម្មសង្គ្រោះបន្ទាន់ ឬសេវាកម្មក្រៅបណ្តាញទៅក្នុងប្រាក់កាត់កងក្នុងបណ្តាញ និងដែនកំណត់ប្រាក់ចំណាយពីហោប៉ៅ។

**បើអ្នកគិតថា គេចេញវិក្កយបត្រខុសឱ្យអ្នក** សូមទាក់ទង៖

នាយកដ្ឋានធានារ៉ាប់រងរដ្ឋ Pennsylvania៖ https://www.insurance.pa.gov/Consumers/Pages/default.aspx

ពាក្យបណ្តឹង-ឬ-សួរ-សំណួរ ឬបណ្តាញជំនួយអ្នកប្រើប្រាស់៖ 1-877-881-6388

· ការិយាល័យរដ្ឋ Pennsylvania នៃអ្នកតស៊ូមតិផ្នែកថែទាំសុខភាពនៅ 877-881-6388 ឬ Healthcare.advocate@pa.gov ។

· • ចូលទៅកាន់គេហទំព័រ https://www.insurance.pa.gov/Coverage/health-insurance/no-surprises-act/Pages/default.aspx សម្រាប់ព័ត៌មានបន្ថែមអំពីសិទ្ធិរបស់អ្នកក្រោមច្បាប់សហព័ន្ធ

**Español (Spanish)**
ATENCIÓN: si habla español, tiene a su disposición servicios gratuitos de asistencia lingüística. Llame al 1-860-679-2626

**Polski (Polish)**
UWAGA: Jeżeli mówisz po polsku, możesz skorzystać z bezpłatnej pomocy językowej. Zadzwoń pod numer 1-860-679-2626

**Português (Portuguese)**
ATENÇÃO: Se fala português, encontram-se disponíveis serviços linguísticos, grátis. Ligue para 1-860-679-2626

**Italiano (Italian)**
ATTENZIONE: In caso la lingua parlata sia l'italiano, sono disponibili servizi di assistenza linguistica gratuiti. Chiamare il numero 1-860-679-2626

**Français (French)**
ATTENTION: Si vous parlez français, des services d'aide linguistique vous sont proposés gratuitement. Appelez le 1-860-679-2626

**繁體中文 (Chinese)**
注意：如果您使用繁體中文，您可以免費獲得語言援助服務。請致電 1-860-679-2626

**Kreyòl Ayisyen (French Creole)**
ATANSYON: Si w pale Kreyòl Ayisyen, gen sèvis èd pou lang ki disponib gratis pou ou. Rele 1-860-679-2626

**Deutsch (German)**
ACHTUNG: Wenn Sie Deutsch sprechen, stehen Ihnen kostenlos sprachliche Hilfsdienstleistungen zur Verfügung. Rufnummer: 1-860-679-2626

**हिंदी (Hindi)**
ध्यान दें: यदि आप हिंदी बोलते हैं तो आपके लिए मुफ्त में भाषा सहायता सेवाएं उपलब्ध हैं। 1-860-679-2626 पर कॉल करें।

**Русский (Russian)**
ВНИМАНИЕ: Если вы говорите на русском языке, то вам доступны бесплатные услуги перевода. Звоните 1-860-679-2626

**ةيبرع (Arabic)**
ملحوظة: إذا كنت تتحدث اذكر اللغة، فإن خدمات المساعدة اللغوية تتوافر لك بالمجان. اتصل برقم 1-860-679-2242x (رقم هاتف الصم والبكم: 1-860-679-2626)

**λληνικά (Greek)**
ΠΡΟΣΟΧΗ: Αν μιλάτε ελληνικά, στη διάθεσή σας βρίσκονται υπηρεσίες γλωσσικής υποστήριξης, οι οποίες παρέχονται δωρεάν. Καλέστε 1-860-679-2626

**Tagalog (Tagalog – Filipino)**
PAUNAWA: Kung nagsasalita ka ng Tagalog, maaari kang gumamit ng mga serbisyo ng tulong sa wika nang walang bayad. Tumawag sa 1-860-679-2626

**Tiếng Việt (Vietnamese)**
CHÚ Ý: Nếu bạn nói Tiếng Việt, có các dịch vụ hỗ trợ ngôn ngữ miễn phí dành cho bạn. Gọi số 1-860-679-2626

**Shqip (Albanian)**
KUJDES: Nëse flitni shqip, për ju ka në dispozicion shërbime të asistencës gjuhësore, pa pagesë. Telefononi në 1-860-679-2626

**한국어 (Korean)**
주의: 한국어를 사용하시는 경우, 언어 지원 서비스를 무료로 이용하실 수 있습니다. 1-860-679-2626 번으로 전화해 주십시오

Printed 12/2021